# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអភិវឌ្ឍន៍ជនបទ

Ministry of Rural Development



# សៀវភៅថវិកាពលរដ្ឋ ឆ្នាំ២០២៤

## Citizen Budget Fiscal Year 2024

ខែមីនា ឆ្នាំ២០២៤

ឆ្នាំ២០២៤

# មាតិកា

ក. សេចក្ដីផ្ដើម........................................................1
ខ. គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ២០២៤......................4
គ. ថវិកាឆ្នាំ២០២៤..................................................8
ឃ. សេចក្ដីសន្និដ្ឋាន....................................................13

# សេចក្តីផ្តើម

ដើម្បីចូលរួមអនុវត្តយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា “ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០២៥០” ក៏ដូចជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០២៤-២០២៨ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២៤-២០២៨ នេះឡើង និងចូលរួមជា មួយរាជរដ្ឋាភិបាលក្នុងយុទ្ធនាការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ, កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយក្នុងនោះក្រសួងអភិវឌ្ឍន៍ជនបទផ្តោតសំខាន់លើអភិក្រមពង្រឹងគុណភាព ៧០% និងពង្រីកវិសាលភាព ៣០% លើការងារអភិវឌ្ឍន៍ជនបទ ដើម្បីពិនិត្យ និងវាយតម្លៃពីប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងសិក្សាពីកាលានុវត្តភាពសំដៅ បង្កើនការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងបានកំណត់ចក្ខុវិស័យគឺ«**កសាងតំបន់ជនបទកម្ពុជាប្រកប ដោយវិបុលភាព, បរិយាប័ន្ន, នវានុវត្តន៍, ឌីជីថល និងភាពធន់ ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌**» សំដៅធានាបាននូវប្រាក់ចំណូលគ្រួសារប្រកបដោយចីរភាព និងមានសុខុមាលភាពកាន់តែល្អប្រសើរឡើង។ ដើម្បីចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់គោលបំណងចំនួន០២គឺ÷

- **បង្កើនប្រាក់ចំណូលតាមគ្រួសារនៅជនបទ** ឱ្យមានជីវភាពសមរម្យ និងមានប្រាក់ចំណូលប្រកបដោយចីរភាព
- **បង្កើនសុខុមាលភាពគ្រួសារនៅជនបទ** ឱ្យមានសុខភាពល្អ និងរស់នៅក្នុងបរិស្ថានស្អាត

# សេចក្ដីផ្ដើម (ត)

ក្នុងឆ្នាំ២០២៤នេះ ក្រសួងអភិវឌ្ឍន៍ជនបទនៅបន្តអនុវត្តកម្មវិធីចំនួន ០៤ ដដែរ ដូចខាងក្រោម÷

១- កម្មវិធីទី១ ÷ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍

២- កម្មវិធីទី២ ÷ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

៣-កម្មវិធីទី៣ ÷ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

៤- កម្មវិធីទី៤ ÷ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

ដោយនៅក្នុងឆ្នាំ២០២៥ ក្រសួងអភិវឌ្ឍន៍ជនបទ បានស្នើសុំរៀបចំរចនាសម្ព័ន្ធកម្មវិធីថ្មី ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា ដែលមានចំនួន ០៥ ដូចខាងក្រោម ÷

1. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ប្រកបដោយភាពធន់
2. លើកកម្ពស់សុខភាព អនាម័យ និងបរិស្ថានរស់នៅរបស់សហគមន៍ជនបទប្រកបដោយនិរន្តរភាព
3. អភិវឌ្ឍន៍សហគមន៍ជនបទ ឌីជីថល និងចលនាភូមិគំរូ
4. ពិពិធកម្មសេដ្ឋកិច្ចជនបទ និងនវានុវត្តន៍ការងារ
5. ពង្រឹងស្ថាប័នតាមរយៈការរៀបចំគោលនយោបាយ ហិរញ្ញវត្ថុ ឌីជីថល និងសហប្រតិបត្តិការ



## ខ.គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ២០២៤

ដើម្បីសម្រេចបានជោគជ័យ ក្រសួងអភិវឌ្ឍន៍ជនបទបាន កំណត់គោលដៅសូចនាករលទ្ធក្នុងឆ្នាំដូចខាងក្រោម ÷

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| **គោលបំណងកម្មវិធីទី១÷** ឱ្យប្រសើរស្ថានភាពផ្លូវជនបទ តាមរយៈការបង្កើនគុណភាព និងការតភ្ជាប់ផ្លូវតំបន់ជនបទ ធានាការប្រើប្រាស់គ្រប់រដូវកាល ដើម្បីលើកកម្ពស់ស្ថានភាព សេដ្ឋកិច្ច និងសង្គមកិច្ច | **សូចនាករទី១÷** ប្រវែងផ្លូវជនបទដែលត្រូវបានស្ថាបនាដោយក្រាលកៅស៊ូ DBST (គ.ម) | ៨៣,៥ គ.ម |
| | **សូចនាករទី២÷** ប្រវែងផ្លូវជនបទដែលត្រូវបានស្ថាបនាបេតុង (គ.ម ) | ២០,៦៤ គ.ម |
| | **សូចនាករទី៣÷** ប្រវែងផ្លូវជនបទដែលត្រូវបានស្ថាបនាដោយក្រាលល្បាយគ្រួស (គ.ម) | ១០៦.៣៦ គ.ម |
| | **សូចនាករទី ៤÷** ប្រវែងផ្លូវជនបទដែលត្រូវបានថែទាំជាលក្ខណៈខួប , ប្រចាំ និងបន្ទាន់ (គ.ម ) | ៤ ២០៤,៤គ.ម |

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| **គោលបំណងកម្មវិធីទី២÷** លើកកម្ពស់លក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទ តាមរយៈការផ្តល់ សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។ | **សូចនាករទី១÷** ចំនួនអណ្តូងទឹកដែលត្រូវបានសាងសង់ | ៣៤០ អណ្តូង |
| | **សូចនាករទី២÷** ចំនួនស្រះទឹកដែលត្រូវបានសាងសង់ | ៥ស្រះ |
| | **សូចនាករទី៣÷** ចំនួនប្រព័ន្ធចែកចាយទឹកស្អាតខ្នាតតូចដែលត្រូវបានសាងសង់ | ៦ប្រព័ន្ធ |
| | **សូចនាករទី៤÷** ចំនួនបង្គន់អនាម័យដែលត្រូវបានសាងសង់ | ៣ ១១៤ បង្គន់ |
| **គោលបំណងកម្មវិធីទី៣÷** លើកកម្ពស់ជីវភាពគ្រួសារនៅជនបទតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន និងវិជ្ជាជីវៈ, | **សូចនាករទី១÷** ចំនួនសិក្ខាកាមដែលទទួលបានការបណ្តុះបណ្តាលអំពីវិធីសាស្ត្រ | ១ ៨៩៤ នាក់ |

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| ការបង្កើតមុខរបរ,សហគ្រិនភាព និងចលនាភូមិគំរូ រួមទាំងការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច ។ | ធ្វើសាប៊ូ.អ៊ុតសក់, ជួសជុលម៉ូតូ, ជួសជុលម៉ាស៊ីនកសិកម្ម និង ធ្វើជីកំប៉ុស្ត កុំព្យូទ័រ ភាសាអង់គ្លេស | |
| | **សូចនាករទី២÷** ចំនួនសិក្ខាកាមដែលទទួលបានការបណ្តុះបណ្តាលអំពីវិធីសាស្ត្របច្ចេកទេស ដាំបន្លែ, ចិញ្ចឹមសត្វ,ចញ្ចឹមត្រី | ៨០០ នាក់ |
| | **សូចនាករទី៣÷** ចំនួនភូមិជនជាតិដើមភាគតិចត្រូវបានកំណត់អត្តសញ្ញាណ | ៨ ភូមិ |
| **គោលបំណងកម្មវិធីទី៤÷** បង្កើនស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពនៃការអនុវត្តថវិកាកម្មវិធីដើម្បីពង្រឹងស្ថាប័ន។ | **សូចនាករទី១÷** ភាពទាន់ពេលនៃការលើកគម្រោងថវិកា | គម្រោងថវិកាត្រូវបានរៀបចំស្របតាមកាលកំណត់នៃសារាចរណែនាំ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ |

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| | **សូចនាករទី២÷** អត្រានៃការអនុវត្តថវិកាសមិទ្ធកម្មរបស់អង្គភាពក្រោមឱវាទក្រសួង | ១០០% |
| | **សូចនាករទី៣÷** ភាពទាន់ពេលនៃការរៀបចំរបាយការណ៍សមិទ្ធកម្ម | របាយការណ៍សមិទ្ធកម្មត្រូវបានរៀបចំស្របតាមកាលកំណត់នៃសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ |

# គ.ថវិកា ឆ្នាំ២០២៤

ក្នុងការសម្រេចឱ្យបាននូវគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលឥណទានក្របខណ្ឌថវិកាឆ្នាំ២០២៤ សរុបចំនួន **៣៦០ ៨២៣ លានរៀល** ទៅតាមកម្មវិធីនីមួយៗ ដូចខាងក្រោម ÷

| | |
|---|---|
| *កម្មវិធីទី១ | **=២៩០ ៤៦៧,៨ លានរៀល** |
| -រដ្ឋបាលកណ្ដាល | =២៧១ ១៦៨,៨ លានរៀល |
| -មន្ទីរអ.ជ.ប រាជធានី ខេត្ត | = ១៩ ២៩៩ លានរៀល |




**កម្មវិធីទី១** ថវិកាឆ្នាំ២០២៤ កើនឡើង ៤% ធៀបនឹងថវិកាឆ្នាំ២០២៣






# គ.ថវិកា ឆ្នាំ២០២៤ (ត)

*កម្មវិធីទី២ = **១១ ៧៥២,៥ លានរៀល**

-រដ្ឋបាលកណ្ដាល = ៩ ៦២៩,៧ លានរៀល

-មន្ទីរអ.ជ.ប រាជធានី ខេត្ត = ២ ១២២,៨ លានរៀល




**កម្មវិធីទី២** ថវិកាឆ្នាំ២០២៤ កើនឡើង ៣.៥% ធៀបនឹងថវិកាឆ្នាំ២០២៣













# គ.ថវិកា ឆ្នាំ២០២៤ (ត)

*កម្មវិធីទី៣ = ៣ ៣៩៤,៩ លានរៀល

-រដ្ឋបាលកណ្តាល = ២ ៦៨៩,៥ លានរៀល

-មន្ទីរអ.ជ.ប រាជធានី ខេត្ត = ៧០៥,៤ លានរៀល




**កម្មវិធីទី៣** ថវិកាឆ្នាំ២០២៤ កើនឡើង ៣,៩% ធៀបនឹងថវិកាឆ្នាំ២០២៣








# គ.ថវិកា ឆ្នាំ២០២៤ (ត)

| | | |
|---|---|---|
| *កម្មវិធីទី៤ | = **៥៥ ២០៧,៨** | **លានរៀល** |
| -រដ្ឋបាលកណ្តាល | = ២៦ ២៣៤ | លានរៀល |
| -មន្ទីរអ.ជ.ប រាជធានី ខេត្ត | = ២៨ ៩៧៣,៨ | លានរៀល |




**កម្មវិធីទី៤** ថវិកាឆ្នាំ២០២៤ កើនឡើង ៩,១% ធៀបនឹងថវិកាឆ្នាំ២០២៣







# គ.ថវិកា ឆ្នាំ២០២៤ (ត)

## គម្រោងចំណាយសម្រាប់ឆ្នាំ២០២៤




❖ កម្មវិធីទី១ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ មាន ៨១% នៃថវិកាឆ្នាំ២០២៤

❖ កម្មវិធីទី២ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ មាន ៣% នៃថវិកាឆ្នាំ២០២៤

❖ កម្មវិធីទី៣ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ មាន ១% នៃថវិកាឆ្នាំ២០២៤

❖ កម្មវិធីទី៤ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅមានថវិកា ១៥% នៃថវិកាឆ្នាំ២០២៤ ។




**ថវិកាឆ្នាំ២០២៤ កើនឡើងចំនួន ៤,៨% ធៀបនឹងថវិកាឆ្នាំ២០២៣ ។**

# ឃ.សេចក្តីសន្និដ្ឋាន

សរុបមកថវិកាឆ្នាំ២០២៤ ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលជួយឱ្យក្រសួងអភិវឌ្ឍន៍ជនបទ ឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ជាពិសេសបាននិងកំពុងចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការស្តារសេដ្ឋកិច្ចឡើងវិញក្រោយពីវិបត្តិជំងឺកូវីដ-១៩ តាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទចំនួន ៤ ដែលបានប្រែក្លាយជាកម្មវិធីសម្រាប់យកទៅអនុវត្តក្នុងគោលបំណងពង្រឹងគុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទឱ្យបានកាន់តែល្អប្រសើរ និងមានភាពសម្បូរសប្បាយរុងរឿង ក្រោមការដឹកនាំប្រកបដោយបញ្ញាញាណរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងនីតិកាលទី៧ ដែលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ មានអាទិភាពគន្លឹះចំនួន ៥ គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យាឌីជីថល ដើម្បីធានាពន្លឿនសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០៕

